# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

លេខ......................

# សារលិខិតរំលែកទុក្ខ

ជូនចំពោះក្រុមគ្រួសារសពលោកអនុសេនីយ៍ត្រី **សួន សំបូរ** ជាទីស្រឡាញ់រាប់អាន !

ក្នុងនាមនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំមានសេចក្ដីក្រៀមក្រំជាអនេកប្បការចំពោះលោកអនុសេនីយ៍ត្រី **សួន សំបូរ** ដែលបានពលីជីវិត កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ក្នុងមន្ទីរពេទ្យកម្រិត៣ ក្នុងប្រទេស Senegal ដោយជម្ងឺគ្រុនចាញ់ ក្នុងនាមជាមន្ត្រីបុគ្គលិកពេទ្យ ក្រុមកម្ទេចគ្រឿងផ្ទុះទី២ នៃកងអនុសេនាតូចកម្ទេចគ្រឿងផ្ទុះ(EOD) ក្នុងក្របខណ្ឌកងអនុសេនាធំកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ៣១២ ដែលបានចូលរួមបំពេញបេសកកម្ម MINUSMA នៅប្រទេសម៉ាលី ។

ការបាត់បង់រូបលោកអនុសេនីយ៍ត្រី **សួន សំបូរ** គឺជាការបាត់បង់នាយទាហានជំនាញឯកទេសដ៏ឆ្នើមមួយរូប ប្រកបដោយវិជ្ជាជីវៈពិតប្រាកដ ដែលបានលះបង់អស់ពីកម្លាំងកាយចិត្ត និងស្មារតី ចូលរួមបម្រើជាតិមាតុភូមិ និងប្រជាជន ព្រមទាំងបានចូលរួមចំណែកដោយស្ម័គ្រចិត្ត ក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ក្នុងនាមមនុស្សធម៌ ។

ក្នុងក្របខណ្ឌនៃការបំពេញបេសកកម្មខាងលើ លោកអនុសេនីយ៍ត្រី **សួន សំបូរ** បានយកចិត្តទុកដាក់អនុវត្តន៍ការងារយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមលើកកម្ពស់កេរ្តិ៍ឈ្មោះ កិត្តិយសជាតិមាតុភូមិ ពិសេសកងយោធពលខេមរភូមិន្ទលើឆាកអន្តរជាតិ ។

ខ្លួនខ្ញុំផ្ទាល់ និងនាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ សូមចូលរួមរំលែកនូវសេចក្ដីទុក្ខដ៏ក្រៀមក្រំក្តុកក្តួលអាឡោះអាល័យជាទីបំផុត ជាមួយក្រុមគ្រួសារញាតិមិត្តទាំងអស់នៃសព និងសូមបួងសួងដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមបីបាច់ក្សាដួងវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី **សួន សំបូរ** បានទៅសោយសុខក្នុងសុគតិភព ជានិច្ចនិរន្តរ៍តរៀងទៅ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមក្រុមគ្រួសារ និងញាតិមិត្តទាំងអស់នៃសព ទទួលនូវមនោសញ្ចេតនា ចែករំលែកទុក្ខដោយក្តីក្រៀមក្រំបំផុតពីយើងខ្ញុំទាំងអស់គ្នា ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍.ទៀ-បាញ់**